雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNANEXPRESS
english.yunnan.cn

ឆ្នាំទី 24 លេខ 6999 ថ្ងៃសុក្រ ទី 08 ខែ មេសា ឆ្នាំ 2016

## "របាយការណ៍ស្រាវជ្រាវ អន្តរជាតិនៃកិច្ចសហប្រតិបត្តិការ ចំពោះសួនឧស្សាហកម្មក្នុងអនុតំបន់ទន្លេមេគង្គ" ត្រូវបានចេញផ្សាយ

**•សួនឧស្សាហកម្មសម្រាប់ពាណិជ្ជកម្មរវាងកំពង់ផែដីគោក គឺមាន សក្តានុពលធំជាងគេ**

*លួ យ៉ុងអាន*

បច្ចុប្បន្ននេះសហព័ន្ធ ឧស្សាហកម្មនិងពាណិជ្ជកម្មនៃខេត្តយូនណាន និងវិទ្យាស្ថានស្រាវជ្រាវការដឹកជញ្ជូនទ្វីបអាស៊ីបានចេញផ្សាយ "របាយការណ៍ស្រាវជ្រាវអន្តរជាតិនៃកិច្ចសហប្រតិបត្តិការចំពោះសួនឧស្សាហកម្មក្នុងអនុតំបន់ទន្លេមេគង្គ"។របាយការណ៍នេះបានចង្អុលបង្ហាញថាសួនឧស្សាហកម្មសម្រាប់ពាណិជ្ជកម្មរវាងកំពង់ផែដីគោក គឺមានសក្តានុពលធំជាងគេ។



ប្រជាពលរដ្ឋកំពុងតែដើរទិញទំនិញនៅតាមបណ្តោយព្រំដែននៃតំបន់សេដ្ឋកិច្ចចិនឡាវម៉ូហាន-ប៊ូតេន (រូបថតដោយ Lei Tongsu )

សួនឧស្សាហកម្មក្នុង "របាយការណ៍"នោះ គឺជាតំបន់ដែលប្រមូលនូវឧស្សាហកម្មគ្រប់ប្រភេទនៅប្រទេសដែលស្ថិតនៅក្បែរទន្លេឡានឆាងចាំង និងទន្លេមេគង្គ ដែលរួមមាន:

-តំបន់ធ្វើតេស្តការអភិវឌ្ឍ និងការបើកចំហជាសំខាន់ច្រកថ្នាក់ជាតិនៅតាមព្រំដែនតំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅតាមព្រំដែនតំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន និងតំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្មក្រៅប្រទេសនៃប្រទេសចិន ។

-តំបន់សេដ្ឋកិច្ចពិសេស និងតំបន់សេដ្ឋកិច្ចនៅតាមព្រំដែននៃប្រទេសភូមា។

-តំបន់សេដ្ឋកិច្ចពិសេស និងតំបន់សេដ្ឋកិច្ចនៅតាមព្រំដែននៃប្រទេសឡាវ។

-តំបន់សេដ្ឋកិច្ចនៅតាមព្រំដែន និងសួនឧស្សាហកម្មនៃប្រទេសថៃ។

-តំបន់សេដ្ឋកិច្ចពិសេស និងតំបន់សេដ្ឋកិច្ចនៅតាមព្រំដែននៃប្រទេសកម្ពុជា ។

-សួនឧស្សាហកម្ម និងតំបន់កែច្នៃនាំចេញនៃប្រទេសវៀតណាម។

-កំពង់ផែលើដីគោកដែលកំណត់ដោយគណៈកម្មាការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ។ល។

"របាយការណ៍" បានលើកឡើងថា របៀបកិច្ចសហប្រតិបត្តិការនៃសួនឧស្សាហកម្មនានា នឹងមានភាពខុសគ្នាដោយផ្អែកលើភាពខុសគ្នានៃស្ថានភាពប្រទេសនានា និងទីតាំងនៃសួនឧស្សាហកម្មនីមួយៗ:

-តំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន គឺសមស្របនឹងរបៀបកិច្ចសហប្រតិបត្តិការដែលដំណើរការស្រេចដោយរដ្ឋាភិបាល។

-តំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅតាមកំពង់ផែ គឺសមស្របនឹងរបៀបកិច្ចសហប្រតិបត្តិការដែលដំណើរការស្រេចដោយទីផ្សារ

-តំបន់សេដ្ឋកិច្ចពិសេសនៅតាមព្រំដែន គឺសមស្របនឹងរបៀបកិច្ចសហប្រតិបត្តិការដែលដំណើរការស្រេចដោយទីផ្សារ ព្រមមានការណែនាំពីរដ្ឋាភិបាល ។

-សួនឧស្សាហកម្មក្នុងទីក្រុងដែលជាមជ្ឈមណ្ឌលសេដ្ឋកិច្ច គឺសមស្របនឹងរបៀបកិច្ចសហប្រតិបត្តិការដែលដំណើរការស្រេចដោយសហគ្រាស ព្រមមានការគាំទ្រពី រដ្ឋាភិបាល។

អំពីការជ្រើសរើសប្រភេទនៃឧស្សាហកម្ម :

-តំបន់សេដ្ឋកិច្ចពិសេសនៅតាមព្រំដែន គឺត្រូវជ្រើសរើសពាណិជ្ជកម្មការដឹកជញ្ជូនការកែច្នៃនាំចេញឃ្លាំងស្តុកទំនិញដែលរក្សាពន្ធជាសំខាន់។

-តំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន ត្រូវជ្រើសរើសកសិកម្ម ទេសចរណ៍ ពិព័រណ៍ ពាណិជ្ជកម្ម ការដឹកជញ្ជូន និងការកែច្នៃនាំចេញជាសំខាន់ ដោយយោងតាមនយោបាយឧស្សាហកម្មនិងការចាត់ចែងនៃរដ្ឋាភិបាលភាគីទាំងពីរ។

-តំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅតាមកំពង់ផែ ត្រូវជ្រើសរើសការដឹកជញ្ជូន កសិកម្ម ជលផល ឧស្សាហកម្មវាយនភណ្ឌ និងឱសថកម្មជាសំខាន់។

-សួនឧស្សាហកម្មក្នុងទីក្រុងដែលជាមជ្ឈមណ្ឌលសេដ្ឋកិច្ចត្រូវ ជ្រើសរើសកសិកម្ម ទេសចរណ៍ វិទ្យាសាស្ត្រ ការអប់រំ និងពាណិជ្ជកម្មជា សំខាន់។

កំពង់ផែអន្តរជាតិលើដីគោកត្រូវជ្រើសរើសពាណិជ្ជកម្ម ការដឹកជញ្ជូនពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងកាត់ព្រំដែន និងហិរញ្ញវត្ថុឆ្លងកាត់ព្រំដែនជាសំខាន់។

អំពីការជ្រើសរើសទីតាំងនៃសួនឧស្សាហកម្មនានា:

-ត្រូវជ្រើសរើសទីតាំងនៃសួនឧស្សាហកម្មកំពង់ផែនៅតាមបណ្តោយទន្លេឡានឆាងចាំងទន្លេមេគង្គ។

-ត្រូវជ្រើសរើសទីតាំងនៃកំពង់ផែអន្តរជាតិលើដីគោកនៅក្នុងទីក្រុងដែលស្ថិតនៅផ្លូវដែកនានានៃបណ្តាញផ្លូវដែកអាស៊ីអាគ្នេយ៍។

-ត្រូវជ្រើសរើសទីតាំងនៃច្រកអន្តរជាតិសំខាន់នានានៅក្នុងតំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន និងតំបន់សេដ្ឋកិច្ចពិសេសនៅតាមព្រំដែន ។

-ត្រូវជ្រើសរើសទីតាំងនៃតំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅតាមកំពង់ផែនៅតាមឆ្នេរមហាសមុទ្រឥណ្ឌានិងប៉ាស៊ីហ្វិក ។

-ត្រូវជ្រើសរើសទីតាំងនៃតំបន់បាតុកម្មកសិកម្មនិងតំបន់ពិសោធន៍វិស័យទេសចរណ៍នៅតាមបណ្តាញដឹកជញ្ជូន។

ទន្ទឹមនឹងនេះ នៅក្នុងកិច្ចសហប្រតិបត្តិការលើសួនឧស្សាហកម្មនានា គឺត្រូវការយន្តការទាក់ទងនឹងយន្តការសម្របសម្រួលរវាងរដ្ឋាភិបាលនានា ដើម្បីផ្តល់បរិវេណកាន់តែល្អសម្រាប់កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន ៕

## ខេត្តយូនណាននឹងកសាងវិទ្យាស្ថានផ្សព្វផ្សាយ អន្តរជាតិចំពោះអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍

*ដោយ : លួ ណាន*

បច្ចុប្បន្ននេះវិទ្យុអន្តរជាតិប្រទេសចិននាយកដ្ឋានឃោសនានៃគណបក្សខេត្តយូនណានសកលវិទ្យាល័យយូនណាន និងសកលវិទ្យាល័យជនជាតិយូនណាន បានចុះហត្ថលេខានៅទីក្រុងគុនមីញ ដើម្បីកសាងរួមគ្នានូវវិទ្យាស្ថានផ្សព្វផ្សាយអន្តរជាតិចំពោះអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។

យោងតាមកិច្ចព្រមព្រៀងនេះ វិទ្យុអន្តរជាតិប្រទេសចិននឹងដឹកនាំគណៈកម្មការអប់រំនៃវិទ្យាស្ថានរៀបចំគម្រោងអប់រំចូលរួមការចាត់ចែងនៃកម្មវិធីសិក្សា ចាត់ចែងគ្រូ ការអនុវត្តផ្តល់មូលដ្ឋានការអនុវត្ត និងទទួលនិស្សិតចូលធ្វើការងារក្នុងវិទ្យុអន្តរជាតិចិនជាអាទិភាព ។ កិច្ចសហប្រតិបត្តិការរវាងភាគីទាំង៤នេះនឹងបណ្តុះបុគ្គលិកខាងផ្សព្វផ្សាយអន្តរជាតិដែលមានគុណភាពខ្ពស់ ដើម្បីបង្កើនការស្រាវជ្រាវចំពោះប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍កសាងបណ្ណាល័យបញ្ញាខាងផ្សព្វផ្សាយចំពោះអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ៕

## ទីក្រុងជីងហុងធ្វើជាម្ចាស់ផ្ទះរៀបចំការ ប្រកួតកីឡានៃស្ថាប័នអនុវត្តន៍ច្បាប់៤ប្រទេស

*ដោយ : ដៃ ជិនហ៊្វា*

បច្ចុប្បន្ននេះសកម្មភាពទាក់ទងខាងកីឡានៃស្ថាប័នការអនុវត្តច្បាប់នៃប្រទេសចិន ឡាវ ភូមា ថៃ លើកទី១ បានប្រារព្ធឡើងនៅទីក្រុងជីងហុង ដោយមានមន្ត្រីអនុវត្តន៍ច្បាប់ដែលមកពីតំបន់ព្រំដែននៃប្រទេសទាំង៤ជាង ១០០នាក់ ចូលរួម ។

តាមដំណឹងថា ចាប់តាំងពីការបង្កើតឡើងនូវយន្តការកិច្ចសហប្រតិបត្តិការសន្តិសុខ និងការអនុវត្តច្បាប់តាមទន្លេមេគង្គនាខែធ្នូ ឆ្នាំ២០១២ មក ភាគីទាំងចិន ឡាវ ភូមា ថៃ បានសហការយ៉ាងជិតស្និទ្ធ ដើម្បីត្រួតពិនិត្យរួមគ្នាស៊ើបអង្កេតរួមគ្នា ផ្លាស់ប្តូរព័ត៌មានរួមគ្នាដោះស្រាយករណីរួមគ្នា និងបម្រើជីវភាពប្រជាជនរួមគ្នា ហើយបានទទួលផលល្អយ៉ាងប្រសើរ ។

ខែធ្នូ ឆ្នាំ២០១៥ រដ្ឋាភិបាលភាគីទាំង៤ បានមូលមតិគ្នាអំពី "យន្តការនៃការប្រារព្ធឡើងនូវសកម្មភាពទាក់ទងខាងកីឡានៃភាគីទាំង៤ ដោយផ្លាស់វេនគ្នា" ។ ពេលមិនយូរប៉ុន្មាននេះ ភាគីទាំង៤បានចាប់ផ្តើមយន្តការនេះនៅទីក្រុងជីងហុង ខេត្តយូនណាន ហើយបានប្រារព្ធនូវព្រឹត្តិការណ៍នេះជាលើកទីមួយ ។ ភាគីទាំង៤ បានរៀបចំការប្រកួតកីឡាវាយសី និងល្បែងទាញព្រ័ត្រជាដើម ៕



ភ្នាក់ងារអនុវត្តច្បាប់មកពីប្រទេសចិនឡាវភូមានិង ថៃចូលរួមការប្រកួតកីឡាបាល់ទាត់មិត្តភាព (រូបថតដោយ Dai Zhenhua )

## គេបានរកឃើញវត្តមាន សត្វការពារថ្នាក់ជាតិ ទីមួយរបស់ចិននៅរដ្ឋឈូស៊្យុងខេត្តយូនណាន

*ដោយ : លី ឃឺវ៉ូ*

បច្ចុប្បន្ននេះគេបានរកឃើញហ្វូងសត្វស្លាបមួយនៅស្រុកស្វាងប៉ៃនៃរដ្ឋឈូស៊្យុង ខេត្តយូនណាន ដែលមានចំនួនប្រហែល៥០ក្បាល ។

ឆ្លងកាត់ការវិភាគចំពោះរូបភាពនៃសត្វស្លាបទាំងនេះ អ្នកជំនាញបក្សីនៃសួនសត្វព្រៃខេត្តយូនណាន បានសម្គាល់ថា សត្វស្លាបទាំងនេះគឺជាសត្វស្លាប Stork ពណ៌ស ដែលជាសត្វការពារថ្នាក់ជាតិទីមួយរបស់ចិន ។ វាបង្ហាញខ្លួននៅខេត្តយូនណានជាហ្វូងៗ គឺកម្រមានណាស់ ។

ឆ្លងកាត់ការវិភាគចំពោះរូបភាពនៃសត្វស្លាបទាំងនេះដែលផ្តល់ដោយអ្នកកាសែត លោកឈាន លីហុង អ្នកជំនាញបក្សីនៃសួនសត្វព្រៃខេត្តយូនណានបានសម្គាល់ថាសត្វស្លាបទាំងនេះគឺជាសត្វស្លាប Stork ពណ៌ស ក៏ហៅថា Stork ចាស់ ។ សត្វ Stork ទាំងនេះមានពណ៌ប្រផេះ និងពណ៌សគឺដោយសារវាមានវ័យនៅក្មេង ដែលមានអាយុតែប្រហែលមួយឆ្នាំប៉ុណ្ណោះតែវាអាចរស់ដោយខ្លួនបាន គ្រាន់តែនៅមិនទាន់ចាស់ទុំ ។ សត្វ Stork ក្មេងគឺស្រដៀងនឹងសត្វ Stork ពេញវ័យ ប៉ុន្តែមានពណ៌ស្រាលជាង ។ វាក្លាយជាសត្វចាស់ទុំដោយសារគេកត់សម្គាល់លើពណ៌នៃចំពុះ និងជើងរបស់វាដោយសារក្លាយជាពណ៌ក្រហមបន្តិច ម្តងៗ ហើយពណ៌ស្លាបវាក៏ក្លាយជាពណ៌ស ។

តាមការណែនាំ សត្វស្លាប Stork ពណ៌ស គឺជាសត្វស្លាបទឹកមួយបែបដែលមានមាឌធំ វាស្អាតណាស់ ហើយគឺជាសត្វការពារថ្នាក់ជាតិទីមួយនៅចិន ។ ហ្វូងសត្វ Stork នេះប្រហែលហើរមកពីទិសខាងជើងចិន ដើម្បីឆ្លងកាត់រដូវរងា ។ ស្របតាមស្ថានភាពអាកាសធាតុវានឹងហើរទៅទិសខាងជើងវិញ ដើម្បីបន្តពូជ ។ នៅរៀងរាល់ខែកញ្ញាឬខែតុលារាល់ឆ្នាំ សត្វស្លាប Stork ពណ៌សនេះ វាតែងតែហើរចេញពីកន្លែងបន្តពូជ ហើយហើរឆ្ពោះទៅទិសខាងត្បូងជាហ្វូងៗ ៕



សត្វស្លាប Stork ពណ៌ស ដែលជាសត្វការពារថ្នាក់ជាតិទីមួយរបស់ ចិននៅស្រុកស្វាងប៉ៃនៃរដ្ឋឈូស៊្យុងខេត្តយូណាន (រូបថតដោយ Li Kewu )

## សហគ្រាសខេត្តយូនណានបានចេញមូលបត្រ បំណុលជាប្រាក់ដុល្លារអាមេរិកនៅក្រៅប្រទេស

*ដោយ : លី ជីហុង*

កាលពីពេលថ្មីៗនេះសហគ្រាសយូនណានវិនិយោគកាន់កាប់ហ៊ុនគ្រុបមានកម្រិតបានចេញលក់មូលបត្របំណុលគ្មានសុវត្ថិភាពចំនួន៣០០ លានដុល្លារអាមេរិក ដែលមានរយៈពេល៣ឆ្នាំនៅលើទីផ្សារមូលធនអន្តរជាតិ ដែលមានអត្រាការប្រាក់ក្នុងមួយឆ្នាំ៣,៣៧ភាគរយ ។

នៅក្រោមជំនួយពីអ្នកសម្របសម្រួលជាសកលទាំង៣ ដែលមានដូចជា សាខាធនាគារហុងកុងម៉េងសងប្រទេសចិន ធនាគារស្វីស និងធនាគារប្រទេសចិនសហគ្រាសយូនណាន វិនិយោគកាន់កាប់ហ៊ុនគ្រុបមានកម្រិតបានរៀបចំពិធីពិព័រណ៍នៅទីក្រុងហុងកុង និងសិង្ហបុរី នាថ្ងៃទី២១ និងថ្ងៃទី២២ ខែមីនា ហើយបានជួបជាមួយក្រុមអ្នកវិនិយោគិនជាស្ថាប័នអន្តរជាតិកំពូលជាង១០០នាក់ ។ អ្នកទទួលខុសត្រូវនៃយូនណានវិនិយោគកាន់កាប់ហ៊ុនគ្រុបមានកម្រិតបានថ្លែងថា ចាប់តាំងពីការបើកការចុះបញ្ជីកាលពីថ្ងៃ២៣ ខែមីនា ក្រុមវិនិយោគិននានាបានចុះបញ្ជីយ៉ាងសកម្មហើយទល់នឹងថ្ងៃត្រង់ដែលជាពេលបិទការចុះបញ្ជីនោះបានទទួលការស្នើសុំទិញជាង១២២ច្បាប់ដែលមានបរិមាណស្នើសុំជាង៣.៥០០លានដុល្លារបានហួសបរិមាណចេញផ្សាយ ជាង១១ដង ។

តាមដំណឹងថា ក្នុងចំណោមអ្នកស្នើសុំទិញទាំងអស់នោះអ្នកនិយោគិននៃទ្វីបអាស៊ីមានដល់ភាគ ៩៤ភាគរយ អ្នកនិយោគិននៃទ្វីបអឺរ៉ុបគឺមាន៦ភាគរយដែរ ។ បើចែកតាមប្រភេទវិនិយោគិនមានស្ថាប័នគ្រប់គ្រងទ្រព្យសកម្មជា៥១ភាគរយ ធនាគារជាង៣២ភាគរយ មូលនិធិមហាក្សត្រ១៧ភាគរយ ក្រុមហ៊ុនមូលបត្រជាង៧ភាគរយ និងមានធនាគារឯកជនជាង៣ភាគរយ មានប្រភេទវិនិយោគិនជាច្រើន ដែលបានបង្កើនកិត្តិនាមនៃសហគ្រាសខេត្តយូនណានមួយនេះ ៕